**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខៈ ០០៦ សណ.ក.ប.ស្ក

ថ្ងៃចន្ទ ១១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩

# សេចក្តីណែនាំ
## ស្តីពី
## ការប្រើប្រាស់ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ សម្រាប់មន្ត្រីឧទ្យានុរក្ស ដែលកំពុងប្រចាំការ នៅតាមតំបន់ការពារធម្មជាតិ

នាពេលថ្មីៗនេះ ក្រសួងពិនិត្យឃើញថា មន្ត្រីថ្នាក់កណ្តាលនៃរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងមន្ត្រីឧទ្យានុរក្សដែលកំពុងប្រចាំការនៅតាមតំបន់ការពារធម្មជាតិ បានខិតខំយកចិត្តទុកដាក់អនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានយ៉ាងល្អប្រសើរ។ ទន្ទឹមនេះ ក្រសួងបរិស្ថាន ក៏សង្កេតឃើញមានមន្ត្រី និងឧទ្យានុរក្សមួយចំនួន បានប្រើប្រាស់ឯកសណ្ឋានពុំទាន់បានត្រឹមត្រូវស្របតាមខ្លឹមសារ នៃអនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ក្រសួងបរិស្ថានឡើយ។

ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពការប្រើប្រាស់ឯកសណ្ឋានស្របតាមលិខិតបទដ្ឋានច្បាប់ ក្រសួងបរិស្ថាន សូមធ្វើការណែនាំដល់មន្ត្រីថ្នាក់កណ្តាលនៃរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងមន្ត្រីឧទ្យានុរក្សដែលកំពុងប្រចាំការនៅតាមតំបន់ការពារធម្មជាតិ ដូចខាងក្រោម៖

- សម្រាប់ឯកសណ្ឋានទៅទីវាល និងឯកសណ្ឋានមន្ត្រីឧទ្យានុរក្ស ត្រូវប្រើប្រាស់ឱ្យស្របតាមអនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ក្រសួងបរិស្ថាន និងប្រកាសលេខ ៣៣៥ ប្រ.ក .បស្ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់រចនាឯកបថបន្ថែម លើសាច់ក្រណាត់សម្រាប់ឯកសណ្ឋានមន្ត្រី នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងមន្ត្រីឧទ្យានុរក្ស និងឯកសណ្ឋានដែលក្រសួងបរិស្ថានបានផ្តល់ជូន។
- ពុំអនុញ្ញាតឱ្យប្រើប្រាស់ឯកសណ្ឋាន សម្ភារភ្ជាប់ដោយពុំមានចែងនៅក្នុងច្បាប់ ឬទិញនៅទីផ្សារឡើយ ដូចជា ខ្សែក្រវាត់ធំ មួកកន្លឹប ស្រដៀងនឹងមួកកន្លឹបដែលមានចែង ក្នុងអនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៥។ល។

ក្រសួងសង្ឃឹមជឿជាក់ថា លោក លោកស្រី ដែលជាមន្ត្រីថ្នាក់កណ្តាលនៃរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត និងមន្ត្រីឧទ្យានុរក្សដែលកំពុងប្រចាំការនៅតាមតំបន់ការពារធម្មជាតិទាំងអស់ បន្ទាប់ពីទទួលបានសេចក្តីណែនាំនេះ នឹងចូលរួមអនុវត្តឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រី**

**សាយ សំអាល់**